UDAYA, Journal of Khmer Studies No. 16, 2025

# យល់ធាតុភូតអស្ចារ្យ

អាំង ជូលាន

ពាក្យ «អស្ចារ្យ» នៅក្នុងចំណងជើងអត្ថបទនេះសំដៅទៅបាតុភូតអ្វីមួយដែលមនុស្សម្នាក់ឬមនុស្សច្រើននាក់ឃើញ ហើយដែលពុំស្ថិតក្នុងដំណើរជាប្រក្រតីនៃធម្មជាតិ [១]។ រីឯពាក្យ «យល់» វិញ គឺប្រើក្នុងន័យបុរាណ។ ខ្មែរបុរាណប្រើពាក្យ យោ៎ល ~ យល [២] ដែលខ្មែរសព្វថ្ងៃច្រើនយកពាក្យ «ឃើញ» មកប្រើជំនួស។ កុំថាឡើយតែបុរាណ មកដល់ចុងសម័យកណ្ដាលហើយក៏គេនៅតែប្រើពាក្យនេះក្នុងន័យដដែល។ ឧទាហរណ៍ស្រង់ពី «ច្បាប់ពាក្យចាស់» ៖

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំ យល់
ទោសគេតូចសោតសល់ រមិល យល់ ប៉ុនទាំងភ្នំ។
(...)
យល់ បាបថាជាបុណ្យ យល់ ឯគុណថានរក
យល់ ល្អថាអាក្រក់ យល់ លាមកថាជាផ្កា។

សូម្បីតែសព្វថ្ងៃក៏នៅប្រើម្ដងៗដែរ ដូចជា ៖

- «ងងិតចក្ខុភ្នែកពុំ យល់» (ងងិតរហូតដល់ភ្នែកមើលមិនឃើញ)។
- «យល់ សប្ដិ» (ឃើញក្នុងសប្ដិ)
- «ខ្ញុំ យល់ ថា» (ខ្ញុំឃើញថា)។ ជួនកាលយើងយកពាក្យ យល់ មកបូកបញ្ចូលជាមួយពាក្យ ឃើញ ទៀតផង ៖ «ខ្ញុំ យល់ឃើញ ថា»។

---

[១] អាត្ភូរ្យ ៖ *Strange appearance, a wonder, miracle, prodigy… (Monier-William 1899) ; Prodige, miracle… (Stchoupak, Nitti, Renou 1959)*។

[២] ទាល់តែមកដល់បច្ចុប្បន្ននេះទើបមានសង្កត់ទៅជា យល់។

ការឃើញអ្វីមួយដែលមានលក្ខណៈចម្លែក ហើយដែលគេជឿថានឹងជះឥទ្ធិពលលើជីវិតពិតប្រាកដក្នុងអនាគតខ្លីឬវែង ពុំមែនទើបតែកើតឡើងថ្ងៃនេះទេ។ ជំនឿនេះមានតាំងពីយូរយារមកហើយ ទោះជាចង់ដឹងថាតាំងពីពេលណាមកក៏ពុំអាចដឹងបាន។ ប៉ុន្តែស្លាកស្នាមចាស់បំផុតដែលសល់មកដល់យើង ដឹងបានតែតាមសិលាចារឹកប៉ុណ្ណោះ។ គឺជំនឿនៅសម័យបុរាណនោះឯង ដែលជាប្រធានបទសំខាន់នៅទីនេះ។

យ៉ាងណាក៏ដោយ មុននឹងបកត្រឡប់ទៅដល់បុរាណកាល គួរនិយាយពីសម័យថ្មីនេះខ្លះៗសិនដើម្បីឲ្យជ្រួតជ្រាបថា ជំនឿខ្មែរសព្វថ្ងៃនិងខ្មែរបុរាណមានមូលដ្ឋានតែមួយទេ។

## ១. សម័យថ្មី

មិនថានៅជនបទឬនៅទីក្រុង យើងតែងឮគេនិយាយពី «ខ្មោចលង» ស្ទើរគ្មានលោះថ្ងៃ មានរហូតដល់បោះពុម្ពជារឿងផ្សព្វផ្សាយផង។ លងនោះមានច្រើនបែប។ ទោះជាមិនបានឃើញខ្មោចតែម្តង ក៏គេតែងលើកយកហេតុអ្វីមួយទៀតដែលបញ្ជាក់ថាជាកលរបស់ខ្មោច[៣] ដូចមានពាក្យថា «ខ្មោចធ្វើកល»។ មានហេតុពីរដែលធ្វើឲ្យខ្ញុំមិនយកប្រការខ្មោចលងមកនិយាយនៅក្នុងអត្ថបទនេះ។ ទីមួយ ទោះជាជឿឬមិនជឿ ក៏ខ្មែរគ្រប់រូបតែងដឹងរឿងខ្មោចលងតិចឬច្រើនហើយដែរ។ ទីពីរជាហេតុសំខាន់ គឺថារឿងទាំងនោះសុទ្ធសឹងជារឿងផ្ទាល់ខ្លួននៃអ្នកដែលនិយាយ ពុំជះឥទ្ធិពលរាលដាលតម្រូវឲ្យសង្គមខ្លួនភ្ញាក់ផ្អើលរហូតដល់ធ្វើកិច្ចអ្វីឡើយ។ ដូច្នេះខ្ញុំនឹងលើកតែរឿងអ្វីដែលពាក់ព័ន្ធតិចឬច្រើនជាមួយសង្គមប៉ុណ្ណោះមកបង្ហាញជាបន្តបន្ទាប់។

ការដែលឃើញអ្វីមួយចម្លែកខ្លាំង ដែលពុំប្រក្រតី ដែលលំបាកនឹងពន្យល់... សុទ្ធសឹងគេចាត់ទុកថាជាបាតុភូតអស្ចារ្យ។ ជួនកាលគេពុំអាចឬក៏ពុំគិតគួរធ្វើអ្វីជាប្រតិកម្មតបតឡើយ ជួនកាលទៀតត្រូវតែរកវិធីដោះស្រាយ ព្រោះបើពុំដូច្នោះអាចនឹងថ្ងោះធ្ងោយការអ្វីមួយ។

### ១.១. បាតុភូតធម្មជាតិមួយនៅភ្នំពេញ

ក្នុងករណីទីមួយ ខ្ញុំសូមលើកឧទាហរណ៍មួយដូចតទៅនេះ។ នារសៀលមួយក្នុងខែសីហា ឆ្នាំ២០០៦ នៅចំមុខព្រះបរមរាជវាំងភ្នំពេញ មានខ្យល់យ៉ាងធំមួយកួចទឹកទន្លេឡើងទៅលើអស់ពេលយ៉ាងយូរ។ មនុស្សម្នាផ្អើលនាំគ្នាមើលបាតុភូតចម្លែកនេះ ហើយនាំគ្នានិយាយថា«នាគលេងទឹក»។ហេតុអ្វីបានជាបកស្រាយថាដូច្នេះ ? នេះគឺមកពីខ្មែរមានរឿង «ព្រះថោងនាងនាគ» ដែលពន្យល់អំពីការករកើតទឹកដីនៃនគរខ្មែរនិងជនជាតិខ្មែរ។ ខ្ញុំពុំនិយាយវែងឆ្ងាយទៀតទេ ដ្បិតធ្លាប់វិភាគរឿងនេះរួចមកហើយ[៤]។ លើកមកនេះ គ្រាន់តែដើម្បីបញ្ជាក់ពីសារសំខាន់នៃការឃើញ (យល់) បាតុភូតចម្លែកដែលពុំតម្រូវឲ្យធ្វើកិច្ចអ្វីទាំងអស់។

---

[៣] សូមមើល *Ang 1980*។

[៤] *Ang 2021 : 166-167*។

## ១.២. មនុស្សកាំបុតត្បូង

ក្នុងករណីទីពីរ ខ្ញុំសូមយកការអេះអាងពីរមកបង្ហាញ គឺការដែលមនុស្សម្នាក់ពេញលេញដើរតាមផ្លូវជាធម្មតា តែបែរជាមានគេឃើញថាមានតែខ្លួនឥតមានក្បាល [៥]។ កាលណាមានបាតុភូតបែបនេះកើតឡើង គេត្រូវតែធ្វើកិច្ចបង្កក់ជាដាច់ខាត ដ្បិតបើពុំដូច្នោះ អ្នកកំបុតត្បូងនោះនឹងមានគ្រោះដល់អស់អាយុស។ ចំណុច ក និង ខ ខាងក្រោមនេះជាពាក្យពេចន៍នៃអ្នកស្រី ប៉ិច រិទ្ធី [៦]។

ក. រឿងទី១ ៖ ថ្ងៃមួយ ប្ដីរបស់បងជីដូនមួយខ្ញុំម្នាក់កំពុងដើរទៅទីណាមួយ ហើយមានគេឃើញថា គាត់ឥតមានក្បាល។ អ្នកឃើញនោះយល់ការភ្ញាម ក៏ប្រញាប់ទៅប្រាប់អ្នកភូមិឲ្យដឹង។ អ្នកភូមិមួយក្រុមក៏ធ្វើជាផ្អើលឆោឡោ ហើយទៅចាប់អ្នកកំបុតត្បូងនោះចងស្លាបសេកហាក់ដូចជាមានកំហុសអ្វីមួយធំណាស់។ អ្នកនោះក៏ភ័យតក្កមា អង្វរគេយ៉ាងណាក៏គេមិនស្ដាប់។ គេនាំអ្នកនោះមកដល់ផ្ទាមួយ ធ្វើដូចជាបម្រុងនឹងកាត់កប្រហារជីវិត។ គេយកដើមចេកមួយដើមដែលខ្ពស់ជាងខ្លួនបន្តិច យកមកកាន់បញ្ឈរពីក្រោយមិនឲ្យដឹងខ្លួន។ មានម្នាក់ទៀតលាក់ខ្លួននៅក្រោយដូចគ្នា ដកដាវកាប់ចុងដើមចេកនោះមួយខ្ទាប់ដាច់ធ្លាក់មកដី។ ឧបកិច្ចនេះហៅថា «កាប់ព្រះម្រិត្យូវ» [៧] គឺជាផ្ដាច់កព្រះម្រិត្យូវ [៨] ដ្បិតគេជឿថា «ព្រះម្រិត្យូវទុំក» អ្នកនោះ។ មនុស្សម្នាក់ទៀត យកទឹកមួយផុងលាយល័ក្តពណ៌ក្រហមមកស្រោចពីលើ សន្មតថាជាឈាម។ មកពីព្រះម្រិត្យូវទុំកដូច្នេះហើយ បានជាអ្នកដទៃទៀតមើលឃើញថាកំបុតត្បូង។ ពេលនោះឯង ទើបអ្នកនោះដឹងខ្លួនថាគេជួយខ្លួនឲ្យផុតពីគ្រោះ ពុំមែនបម្រុងធ្វើបាបឡើយ។

ខ. រឿងទី២កើតឡើងនៅភូមិដដែល។ ម្ដងនោះមានគេឃើញទាហ៊ានម្នាក់កំបុតត្បូង ដើរម្នាក់ឯងឥតគ្នា។ អ្នកដែលឃើញនោះមិនយល់ការអ្វីឡើយ គ្រាន់តែចម្លែកក្នុងចិត្ត។ ស្អែកឡើងទាហ៊ាននោះត្រូវឡានកិនស្លាប់ទាន់ហន់។ ទាល់តែពេលនោះ ទើបអ្នកដែលបានឃើញពីម្សិលប្រាប់ពីការឃើញទាហ៊ានដើរឥតមានក្បាលនោះទៅគេឯងឯទៀត។ ទម្រាំយល់រឿង គឺហួសពេលទៅហើយ។

---

[៥] សូមកុំច្រឡំនឹងជំនឿលើអាប។ គេនិយាយថាយប់ខ្វះ ពេលទើបនឹងភ្លៀងរួច មនុស្សស្រីដែលជាអាបទុកដងខ្លួននៅដេកក្នុងផ្ទះស្ងួកស្ងឹង រីឯក្បាលនឹងពោះវៀនពោះតាំងចេញទៅរកស៊ីគ្រឿងឆ្អាបនៅឯក្រៅស្ងាត់ៗក្នុងទីងងឹត។ មនុស្សកំបុតត្បូងនៅទីនេះពុំមែនដូច្នេះឡើយ គឺខ្លួនប្រាណពេញលេញដើរនៅពេលថ្ងៃតាមផ្លូវជាធម្មតា ស្រាប់តែមាននរណាម្នាក់ឃើញថាឥតក្បាលទៅវិញ។

[៦] រឿងទាំងពីរនេះ អ្នកស្រីបាននិយាយប្រាប់ខ្ញុំកាលពីឆ្នាំ១៩៨១ ហើយខ្ញុំបានចុះផ្សាយនៅក្នុង *Ang 1986 : 83-84*។

[៧] ស្ដាប់ទៅព្ទស្សូរថា /kap pəmatəyɤv/។

[៨] នៅក្នុងសាសនាព្រាហ្មណ៍ ម្ឫត្យុ ជាទេពនៃសេចក្ដីស្លាប់។

*រឿងឃើញមនុស្សធម្មតាទៅជាកំបុតត្បូងបែបនេះ កាលពីមុនហាក់ដូចជាសម្បូណ៌ដែរ ដូចអាចឃើញក្នុងការកត់ត្រានៃអ្នកស្រាវជ្រាវឬអ្នកនិពន្ធជាន់មុនខ្លះៗ [៩]។*

*ករណីទាំងពីរដែលបានលើកមកនេះសុទ្ធតែទាក់ទងនឹងការឃើញ (យោលិ ~ យលិ ~ យល់) ហើយជាមួយគ្នានោះ ទាក់ទងនឹងសង្គម។ កាលទឹកក្ដួចនៅមុខវាំង មនុស្សនៅទីនោះ ក្នុងពេលនោះ បានឃើញគ្រប់គ្នា ហើយបកស្រាយបាតុភូតនោះតាមរឿងព្រះថោងនាងនាគដែលជារឿងខ្មែរស្គាល់ទាំងអស់គ្នា។ មនុស្សកំបុតត្បូងក៏ទាក់ទងនឹងការឃើញ (យោលិ ~ យលិ ~ យល់) ដែរ គ្រាន់តែជាការឃើញដោយមនុស្សម្នាក់តែដែលតម្រូវឲ្យសង្គមទាំងមូលដោះស្រាយបញ្ចៀសផលវិបាក។*

*ការដែលនរណាម្នាក់អះអាងថាបានឃើញបាតុភូតអ្វីមួយអស្ចារ្យស្ដែងនឹងភ្នែក របៀបដូចបានឃើញមកហើយនេះមានញឹកញាប់ជាពន់ពេក មិនអាចរាប់អស់ឡើយ។ ឯជំនឿលើការឃើញក្នុងសប្ដិ (យល់សប្ដិ) ទាក់ទងទៅនឹងបាតុភូតជាក់ស្ដែងក៏នៅតែរស់រវើកដូចគ្នា [១០]។ ដូច្នេះហើយបានជាមានតម្រាកាត់សប្ដិច្រើនបែបយ៉ាង។ ខាងក្រោមនេះ ជាឧទាហរណ៍មួយដែលគួរឲ្យចាប់អារម្មណ៍។*

## ១.៣. សុបិន្តក្លាយជាពិត

*នៅជំនាន់អាណាព្យាបាលបារាំង ព្រះសង្ឃមួយអង្គព្រះនាមសែម សរសេរលិខិតមួយច្បាប់ទៅលោករ៉េស៊ីដង់ស៊ុប៉េរីយើរ [១១] ដោយសារតែមានគេ (អាជ្ញាធរបារាំង ?) ហាមឃាត់មិនឲ្យលោកព្យាបាលជម្ងឺអាសន្នរោគដោយប្រើឱសថដែលលោកស្គាល់តាមសប្ដិ។ ព្រះតេជគុណសែមមានកំណើតនៅខេត្តកំពត ហើយបួសនៅវត្តមួយក្នុងខណ្ឌទូកមាស។ ប៉ុន្តែពេលដែលតាក់តែងសំបុត្រនោះ លោកគង់នៅវត្តកោះ ក្នុងទីក្រុងភ្នំពេញ។*

*ពាក្យពេចន៍ដើមជាខ្មែរមិនដឹងនៅឯណាទេ យើងមាននៅសល់តែពាក្យដែលវេជ្ជបណ្ឌិតបារាំងឈ្មោះ Bernard Menaut ប្រែជាភាសាបារាំងទៅហើយ [១២]។ ខ្ញុំកាត់ចោលពាក្យឬឃ្លាខ្លះដែលពុំមានប្រយោជន៍នៅទីនេះដោយប្រើ (...)។ រីឯសញ្ញា ---------- វិញ គឺជាពាក្យដែលលោក Menaut កាត់ចោលពីនាយមក ហើយខ្ញុំក៏ពុំដឹងថាដោយហេតុអ្វីដែរ។*

---

[៩] *ជាឧទាហរណ៍ សូមមើល Aymonier 1883 : 174-175 និង Branda 1887 : 256។*

[១០] *មានឧទាហរណ៍នៅក្នុង Ang 1986 : 153, 176-178។*

[១១] *«រ៉េស៊ីដង់ស៊ុប៉េរីយើរ» (Résident Supérieur) តាំងទីនៅភ្នំពេញ ហើយអំណាចគាត់វាតទីលើប្រទេសកម្ពុជាទាំងមូល ជួសមុខឲ្យអាណាព្យាបាលបារាំង។*

[១២] *Menaut 1930 : 31។*

យល់បាតុភូតអស្ចារ្យ

*Phnom Penh, le 10 septembre 1928*

*Monsieur le Résident Supérieur,*

*Je soussigné SEM, bonze cambodgien ----------, domicilié à la pagode de Wat Kas, 5ème quartier de la Ville de Phnom Penh (…).*

*Au cours de ces dernières années une épidémie de choléra a fait de nombreuses victimes dans le Khum de Banteay Meas (…).*

*Voyant le fléau (…) j'ai adressé de ferventes prières aux Dieux et à Bouddha (…). Durant une nuit entière, j'ai prié avec ferveur puis me suis endormi. J'ai rêvé, Feu Sa Majesté SISOWATH m'est apparue tenant en mains divers médicaments dont Elle m'expliquait l'emploi, et m'invitant à les utiliser pour combattre le fléau.*

*Dès le lendemain, j'ai donné la médication à prendre à des malades qui sont tous guéris : aucun de ceux que j'ai soignés n'est mort au cours de cette épidémie aujourd'hui disparue.*

*(…)*

*Nous devons, moi qui suis bonze, tout comme ceux qui ne le sont point, consacrer tous nos efforts au sauvetage des malheureux, de quelle race qu'ils soient. Aussi suis-je profondément affligé de connaître ce médicament et de ne pouvoir l'utiliser pour secourir les victimes de l'épidémie actuelle.*

*Pour ces motifs ----------, je demande à être autorisé à soulager ces malheureux, certain de n'en laisser succomber aucun. Je le ferai sans demander quoi que ce soit en échange de mes soins. Nul intérêt personnel, nul souci de renommée ne saurait guider un bonze cambodgien dont la vie n'a qu'un but, le bonheur des autres, par la pitié et la charité.*

*Votre obéissant bonze,*
*SEM*

ខ្ញុំសូមប្រែសម្រួលបន្តិចបន្តួចខ្លះដូចតទៅ ៖

ភ្នំពេញ ថ្ងៃទី១០កញ្ញា ១៩២៨

សូមជម្រាបមកលោករ៉េស៊ីដង់ស៊ុប៉េរីយើរ,

អាត្មាភាពមាននាមថា សែម ជាព្រះសង្ឃខ្មែរ ---------- គង់នៅវត្តកោះ សង្កាត់លេខ៥ ទីក្រុងភ្នំពេញ (...)។

ប៉ុន្មានឆ្នាំមកនេះ មានអាសន្នរោគរាតត្បាត បង្ករឲ្យមនុស្សរងគ្រោះច្រើន នៅឃុំបន្ទាយមាស (...)។

ដោយឃើញមហន្តរាយបែបនេះ (...) អាត្មាភាពក៏បានខិតខំបន់ស្រន់ទៅដល់ទេពនានា ព្រមទាំងទៅដល់ព្រះពុទ្ធអង្គ (...)។ អាត្មាភាពបន់ស្រន់យ៉ាងស្វិតស្វាញពេញមួយយប់ រួចហើយទើបសឹង។ ពេលនោះអាត្មាយល់សប្តិថា ព្រះសពព្រះករុណាព្រះបាទ

ស៊ីសុវត្ថិ [១៣] យកថ្នាំផ្សេងៗមកដាក់ក្នុងដៃអាត្មា ដោយពន្យល់អំពីរបៀបប្រើ ហើយប្រាប់ឲ្យអាត្មាយកទៅព្យាបាលកំចាត់ឧត្បាតចង្រៃនោះ។

ព្រឹកឡើងភ្លាមអាត្មាក៏យកថ្នាំទៅព្យាបាលអ្នកជម្ងឺទាំងនោះផឹកបានសះស្បើយគ្រប់គ្នា គ្មាននរណាម្នាក់ដែលបានទទួលការព្យាបាលហើយនៅតែស្លាប់ទេ [១៤]។ សព្វថ្ងៃជម្ងឺធ្ងន់នេះសាបសូន្យអស់ហើយ ។

(...)

អាត្មាភាពដែលជាសង្ឃក្តី អ្នកឯទៀតដែលជាគ្រហស្ថក្តី យើងទាំងអស់គ្នាត្រូវតែព្យាយាមខិតខំរួមគ្នាស្រោចស្រង់ជនអភ័ព្វទាំងនោះ  មិនថាសាសន៍ណាឬសាសន៍ណាឡើយ។ នេះជាហេតុដែលអាត្មាភាពសោកស្តាយយ៉ាងខ្លាំង ដោយសារថាស្គាល់ថ្នាំហើយតែពុំអាចយកមកព្យាបាលអ្នករងគ្រោះជម្ងឺរាតត្បាតនាបច្ចុប្បន្ននេះ [១៥]។

សេចក្តីដូចបានពោលមកនេះ ---------- អាត្មាភាពសូមការអនុញ្ញាត្តិស្រោចស្រង់ជនអភ័ព្វទាំងនោះ ដោយជឿជាក់ក្នុងចិត្តថានឹងអាចស្រោចស្រង់បានឥតសល់ម្នាក់ឡើយ។ អាត្មានឹងមិនទាមទារកម្រៃអ្វីទាំងអស់ក្នុងការព្យាបាលនោះ។ បួសជាសង្ឃហើយ ពុំត្រូវគិតប្រយោជន៍ផ្ទាល់ខ្លួន  ពុំត្រូវប៉ងចង់ល្បីឈ្មោះអ្វីទាំងអស់  ដ្បិតសង្ឃត្រូវមានសេចក្តីប្រាថ្នាតែមួយ គឺសុខនៃអ្នកដទៃ ដោយចិត្តអាណិតសប្បុរស។

ពីសង្ឃដែលនៅក្រោមឱវាទលោក

សែម

ឥឡូវនេះ គប្បីយើងត្រឡប់ក្រោយមើលទៅសម័យយូរមកហើយវិញ ដើម្បីដឹងថាតើជំនឿលើការឃើញនឹងភ្នែកស្រស់ៗឬក៏ការឃើញក្នុងសប្តិមានដែរឬទេ។

## ២. សម័យបុរាណ

ប្រភពទិន្នន័យមានតែមួយទេ គឺសិលាចារឹក។ ដូចយើងដឹងស្រាប់ អក្សរថ្មសម័យបុរាណប្រើភាសាពីរ គឺខ្មែរនិងសំស្ក្រឹត ជួនកាលប្រើតែមួយមុខ ជួនកាលទៀតប្រើទាំងពីរចូលគ្នា [១៦]។ កាលណាគេពោលពាក្យ

[១៣] លិខិតនេះសរសេរនៅឆ្នាំ១៩២៨ ឯព្រះករុណាព្រះបាទស៊ីសុវត្ថិចូលទីវង្គតនៅឆ្នាំ១៩២៧។

[១៤] ស្តាប់ត្រង់នេះទៅធ្វើឲ្យយើងគិតឬឆ្ងល់ថា ថ្នាំនោះឃើញក្នុងសប្តិទេ តែស្រាប់តែព្រឹកឡើងរកបានភ្លាម។

[១៥] អះអាងត្រង់នេះហាក់ដូចជាផ្ទុយគ្នានឹងសេចក្តីនៅខាងលើដែលថាជម្ងឺធ្ងន់នោះសាបសូន្យអស់ហើយ។ ឬមួយក៏សេចក្តីប្រែលិខិតដើមមកជាបារាំងមានគ្លាំគ្លង ?

[១៦] កាលណាសិលាចារឹកនោះជាសំស្ក្រឹត ខ្ញុំពុំមានសមត្ថភាពប្រែពីសេចក្តីដើមមកជាខ្មែរទេ គឺប្រែបានតែពីសេចក្តីដែល

*លើកតម្កើងទេពនានា ដោយមានរំឭកឈ្មោះអ្វីមួយពីទេពកបាងផង គេតែងរៀបរាប់ជាកាព្យសំស្ក្រឹត។ ពាក្យលើកតម្កើងសរសើរព្រះរាជាក៏ដូចគ្នា គឺថាប្រើឃ្លាឃ្លោងជាសំស្ក្រឹត។ ក្នុងការលើកព្រះរាជានេះ ជាញឹកញាប់ណាស់ដែលអ្នកនិពន្ធលើកព្រះអង្គរហូតដល់ថាមានអានុភាពឬក៏មានគុណសម្បត្តិអ្វីមួយលើសទេពទៅទៀតផង។ បាតុភូត «អស្ចារ្យ» ដែលខ្ញុំនឹងលើកឡើងបន្តិចខាងមុខ មិនសំដៅទៅលើប្រការនេះឡើយ។ ខ្ញុំនឹងស្រង់យកតែហេតុភេទចម្លែកអ្វីដែលសិលាចារឹកអះអាងថា មានគេបានឃើញផ្ទាល់ភ្នែក នៅទីផ្សេងៗនៃប្រទេសកម្ពុជា។*

## ២.១. សិលាចារឹកគោកចក, K. 521, ផ្នែកទី២នៃស.វ.ទី១១, ភាសាខ្មែរ [17]

*សេចក្តីចារនៅលើមេទ្វារប្រាសាទនេះ រៀបរាប់ពីកម្មសិទ្ធដីធ្លីដែលស្ត្រីម្នាក់រស់នៅផ្នែកទី២នៃស.វ.ទី១១ ទទួលតគ្នាច្រើនជំនាន់ជាមរតកពូជពង្សរៀងមក។ តាមការអះអាងនៃម្ចាស់សិលាចារឹក ដីជាមរតកនេះ ដើមឡើយជាព្រៃ តែក្រោយមកក្លាយជាដីស្រុក ដ្បិតកាលពីគ.ស.៨៥០ (ប្រមាណ២០០ឆ្នាំមុនមានចារឹកនោះ) ព្រះបាទជ័យវម៌ទី៣បានត្រាស់បង្គាប់ឲ្យគេឆ្ការក្រោយពីមានបាតុភូតអស្ចារ្យមួយកើតឡើងក្នុងឱកាសដែលព្រះអង្គទាក់ដំរីនៅទីនោះ។ ដីស្រុកដែលកើតឡើងពីការរានព្រៃ ព្រះអង្គប្រទានមួយភាគឲ្យទៅបុព្វការីនៃស្ត្រីនោះឯង។*

*គេអាចសង្ខេបរឿងឲ្យខ្លីដូចតទៅ ៖ នាគ.ស.៨៥០ ព្រះបាទជ័យវម៌ទី៣យាងមកទាក់ដំរី តែដំរីដែលទាក់បានទៅជារត់រួច(មកពីព្រ័តដាច់?)ហើយគេចខ្លួនមកម្តុំប្រាសាទគោកចកដែលកាលនោះនៅជាព្រៃនៅឡើយ ៖* តំម្រី រត៑ ចូល៑ ត វ្រៃ នេះ *(«ដំរីរត់ចូលក្នុងព្រៃនេះ»)។ ក្នុងការតាមរក ដល់ពេលយប់ឡើងព្រះរាជាផ្ទុំនៅទីនេះតែម្តង ៖* យប៑ ផ្ទុំ ត គិ*។ នៅពេលផ្ទុំ ព្រះអង្គបន់ស្រន់ (ទៅទេពណាមួយដែលគេមិនបញ្ជាក់) សូមប្រទះនឹងហេតុភេទអ្វីមួយឲ្យបានស្តែង ៖* សុំ ប្រត្យាទេឝ*។ ពេលផ្ទុំលក់ទៅ ព្រះអង្គក៏ឃើញមានទេពក្នុងនិកាយព្រះនារាយណ៍មួយអង្គមកបង្ហាញខ្លួន ហើយមានបន្ទូលមកព្រះអង្គក្នុងសុបិន្ត ៖* យោល៑ កម្រតេង៑អញ៑ វ្នៅ ម្វាយ៑ បន្ទូល៑ វ្រះចាន៑វិស្ណុលោក [18]*។ ព្រះបន្ទូលទេពនោះគឺ ៖* ទហា ញ្យាន វិ--- [19] ប៑ ស្តាប រូបអញ៑ កត្តិយអញ៑ ឲ្យ តំម្រី ដោះ វិញ៑ *សម្រួលមកថា «បើឯងខំ--- ហើយសាងរូបអញ កក្តីអញ អញឲ្យដំរីនោះវិញ»។* ឧទៃយ គុះ អំចាង៑ តំម្រី ដោះ ត វ្រៃ នេះ *គឺថាគ្រាន់តែព្រហាមស្រាងឡើង ដំរីនោះក៏បានមកវិញក្នុងព្រៃនោះមែន។ ចារឹកថ្មប្រាប់យើងតទៅទៀតថា ព្រះរាជាប្រើ*

---

*អ្នកប្រាជ្ញកាលមុនប្រែជាភាសាបារាំងឬអង់គ្លេសរួចទៅហើយ។ ប៉ុន្តែយ៉ាងណាក៏ខ្ញុំជឿថា អស់លោកទាំងនោះបានខំប្រែពុំឲ្យមានល្បឿនខ្លាំងដែរ។ ទោះជាសេចក្តីនោះជាភាសាខ្មែរ ក៏ខ្ញុំនៅតែផ្អែកលើការសិក្សាពីអ្នកប្រាជ្ញមុន គ្រាន់តែខ្ញុំអាចផ្ទៀងផ្ទាត់និងសម្រួលបានខ្លះ។*

[17] *Cœdès 1952 : 167-170*។

[18] វិស្ណុលោក *ជាមរណនាមនៃព្រះបាទជ័យវរ្ម័នទី៣។*

[19] *ត្រង់នេះថ្មបែក ធ្វើឲ្យបាត់ពាក្យខ្លះ។*

ឲ្យគេផ្ការព្រៃនោះដើម្បីសាងទីបូជាមួយតម្កល់ប្រតិមាព្រះ ឥកាព្រហ្មាណា ហើយរៀបចំដីព្រៃនោះឲ្យទៅជាស្រុកភូមិ ហៅថា វិឞ្ណុគ្រាម។

ព្រឹត្តិការណ៍រៀបរាប់នៅសិលាចារឹកគោកចកនេះ មានលំនាំដូចគ្នានឹងព្រឹត្តការណ៍ដែលព្រះតេជគុណសែមអះអាងនៅខាងលើ គឺថាអ្វីដែលបានឃើញក្នុងសប្តិ បន្ទាប់មកក្លាយជាការពិត។ ព្រះបាទជ័យវម៌ទី៣បានឃើញ (យោល់) ព្រះនារាយណ៍[២០] ក្នុងសប្តិ។ ឯក្នុងសប្តិព្រះតេជគុណសែមវិញ ទោះបីពុំមែនជាទេពសុទ្ធសាធ ក៏គង់ជាព្រះរាជា[២១] ដែលកំពុងសោយសុខនៅស្ថានទេពដែរ[២២]។

## ២.២. សិលាចារឹកព្រះវិហារ (កំពង់ឆ្នាំង), K. 733, ស.វ.ទី៧, ភាសាសំស្ក្រឹត[២៣]

តួអង្គក្នុងសិលាចារឹកនេះជាអ្នកប្រាជ្ញម្នាក់ឈ្មោះ វិទ្យាបុឞ្ប ដែលនៅបម្រើព្រះមហាក្សត្រ (ព្រះបាទភវវម៌ទី២ ?)។ ល្បះ៦-៧ និយាយថា ក្នុងដំណើរធម្មយាត្រាទៅវន្ទាបូជនីយស្ថានផ្សេងៗ គាត់យល់សប្តិថា ព្រះឥសូរនាំគាត់មកដល់ភ្នំ តុង្គីឝបវ៌ត[២៤] «នៅទីនេះ»[២៥] តែម្តង ៖

> ក្នុងដំណើរយាត្រាទៅសំពះបូជនីយស្ថាន មានប្រាសាទនិងភ្នំនានា គាត់មកដល់ទីនេះក្នុងសប្តិ ដោយមានព្រះអង្គកាន់ត្រីសូល[២៦] ជាអ្នកនាំមក។ ក្រោយមក នៅទីនេះ គាត់បានឃើញ[២៧] លិង្គនៃព្រះគង្ករ[២៨], ព្រះបាទ, ថ្មុកទឹក ព្រមទាំងផ្ទះ នៅលើ [ភ្នំ] តុង្គីឝបវ៌ត ដូចកាលឃើញក្នុងសប្តិដូច្នោះ។

*K. 733* ខាងលើនេះក៏គ្មានខុសអ្វីពី *K. 521* (គោកចក) ព្រមទាំងរឿងព្រះតេជគុណសែមដែរ ដ្បិតជាប្រការដែលសុបិន្តក្លាយជាការពិតដូចគ្នា។

---

[២០] ឬក៏ទេពអង្គណាមួយក្នុងនិកាយព្រះនារាយណ៍មានព្រះក្រឹស្ណាជាដើម។

[២១] ព្រះរាជានុកោដ្ឋ ពោលគឺព្រះសពព្រះករុណាព្រះបាទស៊ីសុវត្ថិ។

[២២] ព្រះរាជាមិនស្លាប់ទេ គឺ សុគត (យាងទៅភពល្អ), ចូលទីវង្គត (យាងចូលទៅស្ថានទេព)។ អ្នកខ្មែរនៅសុរិន្ទ្រ (ប្រទេសថៃឡង់ដ៍) និយាយថា /sorəkut/ ដោយនៅបញ្ចេញសម្លេង /r/ (ដូចជា «ពីរ» នៅអានថា /pir/ ដែរ គឺថាមិនទាន់បាត់សម្លេង /r/ នៅឡើយ)។ ត្រង់នេះហើយដែលបង្ហាញថាជាប់ទៅនឹងខ្មែរបុរាណ ស្វគ៌គត (ដែលយាងទៅស្ថានសួគ៌) ដ្បិតពីដើមគេអានរេផទេចេញជាសម្លេង /r/។

[២៣] នៅទីនេះខ្ញុំយកតែសេចក្តីខ្មែរមកនិយាយ។ សូមមើល *Cœdès 1937 : 3-5*។

[២៤] គឺភ្នំព្រះវិហារ (ស្រុកកំពង់លែង, ខេត្តកំពង់ឆ្នាំង)។

[២៥] គឺត្រង់ទីតាំងដើមនៃសិលាចារឹកនេះឯង។

[២៦] ព្រះឥសូរ។

[២៧] ឃើញពិតប្រាកដ ក្នុងការមកដល់ពិតប្រាកដ ពុំមែនក្នុងសុបិន្តទៀតទេ។

[២៨] លិង្គព្រះឥសូរ។

## ២.៣. សិលាចារឹកភិមានអាកាស, K. 484, ស.វ.១២-១៣, អត្ថបទតែមួយ ជាសំស្រ្កឹតនៅផ្ទាំងម្ខាង និងខ្មែរនៅផ្ទាំងម្ខាងទៀត [២៩]

*សេចក្តីនៅលើផ្ទាំងថ្មតូចនេះទាក់ទងទៅនឹងពោធិមួយដើមដែលគេដាំនៅមិនឆ្ងាយប៉ុន្មានពីជណ្តើរខាងកើតនៃប្រាសាទភិមានអាកាស ក្នុងព្រះរាជវាំងអង្គរធំ។ ពាក្យពេចន៍ក្នុងនោះអះអាងថាឫសនៃពោធិនោះជាព្រះព្រហ្ម ដើមជាព្រះឥសូរ មែកជាព្រះនារាយណ៍។ មានសេចក្តីបែបន់ផ្សេងៗដែលគេធ្វើឆ្ពោះទៅពោធិនោះ។ បន់ទីមួយ គឺអ្នកបន់សូមឲ្យព្រះពោធិខ្លួនឯងចៀសផុតពីគ្រោះថ្នាក់ ៖* កាំ បិ រន្ទះ បញ្ញាំ កម្រតេង៑ អញ្ញាំ កាំ បិ ត្រូ តិង៑ កាំ បិ វ្រះវាយុ កាច *សម្រួលមកថា «កុំបីរន្ទះបាញ់ព្រះអង្គ កុំបីមាននរណាយកដឹងមកកាប់ កុំបីខ្យល់បក់បោកមកខ្លាំងបណ្តាលឲ្យបាក់រលំ»។ បន់ទីពីរ ៖* ដោ កម្រតាង៑ ផ្ទាង៑ យេង៑ ត អសរុ ដោ កម្រតាង៑ ចំចេំ ត អសរុ ដោ ស្វប្ន ត អសរុ (...) ចុរ បំបត ដោះ *គឺអ្នកបន់សូមឲ្យព្រះពោធិជួយខ្លួនកុំឲ្យប្រទះប្រការចង្រៃមានញាក់ភ្នែក ញាក់ចិញ្ចើម [៣០] និងយល់សប្តិអាក្រក់ជាដើម។*

*នៅផ្នែកក្រោយនៃសិលាចារឹកនេះយើងឃើញថាយល់សប្តិ [៣១] ជាបាតុភូតិដែលគេចាត់ទុកថានៅក្រៅដំណើរធម្មជាតិដូចធ្លាប់ឃើញនៅចារឹកមុនៗដែរ។*

## ២.៤. សិលាចារឹកព្រះវិហារ, K. 380, គ.ស.១០៣៧, ភាសាខ្មែរ [៣២]

*អទិទេពនៅប្រាសាទព្រះវិហារមានព្រះនាមថា* ស្រីសិខរេស្វរ*។*

*- នៅមេទ្វារខាងលិចនៃខ្លោងទ្វារ D, ប.១៤-១៥ មានពាក្យថា ៖* វ្រះសិវតេជះ កម្រតេង៑ជគត ស្រីសិខរីស្វរ ត យល ប្រត្យក្ស ប្រាទុភាវ [៣៣] *ដែលអាចប្រែសម្រួលមកថា «ព្រះស្រីសិខរេស្វរមកបញ្ចេញតេជះជាព្រះឥសូរ បង្ហាញខ្លួនឲ្យគេឯងឃើញច្បាស់នឹងភ្នែក» (នៅក្នុងទេសកាលអ្វីមួយដែលយើងពុំដឹងច្បាស់)។*

*ទោះបីមានទេពជាចម្បង ពោលគឺព្រះស្រីសិខរេស្វរហើយក្តី ក៏ព្រះបាទសូរ្យវម៌ទី១ដែលជាអ្នកសាង*

[២៩] *Cœdès 1918។*

[៣០] *ញាក់ដោយសារសសៃទាញ ពុំមែនញាក់ដោយចេតនាទេ។*

[៣១] *គេប្រើពាក្យ* ស្វប្ន *ដែលជានាម។*

[៣២] *Cœdès 1954 : 257-270។*

[៣៣] *ពាក្យ* ប្រត្យក្ស *និង* ប្រាទុភាវ *មានន័យប្រហាក់ប្រហែលគ្នា គឺថា «ចំពោះមុខ», «ស្តែងចំមុខ»។ មុននោះមានពាក្យ* យល*។ កំណាត់ឃ្លានេះអាចសម្រួលមកថា «ឃើញស្តែងនឹងភ្នែក»។*

*ព្រះវិហារ បានតាំងសីលការនាស្មឹងស្មាធិ៍ ធ្វើតបស [៣៤] ដើម្បីយាងព្រះភទ្រេស្វរដែលជាអទិទេពនៃវត្តភូ [៣៥] ឲ្យមកសន្និតគង់នៅព្រះវិហារផង [៣៦]។*

- *មេទ្វារខាងកើតនៃខ្លោងទ្វារ D, ប.៣-៥ ៖* មធិ កម្រតេងជគត៑ ស្រីភទ្រេស្វរ លិង្គបុរ មោត៑ បុនភ៌ាវ [៣៧] អាយ៑ ស្រីសិខរីស្វរ ប្យ៑ ត៑ វ្រះតេជះ ត យល៑ ប្រត្យក្ស ប្រាទុភ៌ាវ *សម្រួលមកថា «ព្រះស្រីភទ្រេស្វរដែលជាទេពនៅលិង្គបូរ យាងមកប្រសូត្រនៅស្រីសិខរេស្វរ ដោយបញ្ចេញតេជះឲ្យជនទូទៅឃើញច្បាស់នឹងភ្នែក»។*

*នៅសម្រង់ទាំងពីរខាងលើនេះ គេពុំត្រឹមតែប្រើពាក្យ យល៑ ប៉ុណ្ណោះទេ គឺគេសង្កត់បន្ថែមថា* ប្រត្យក្ស ប្រាទុភ៌ាវ *ដើម្បីបញ្ជាក់ថាឃើញស្ដែងច្បាស់ទៅទៀត [៣៨]។*

- *មេទ្វារដដែល, ប.៥៨-៦០ ៖* មធិ កម្រតេង ជគត៑ ស្រីភទ្រេស្វរ លិង្គបុរ ត៑ វ្រះបាទកម្រតេងកំត្វង៑អញ៑ ស្រីសូយ៌្យវម្មទេវ សាធ្យ ទុ វ្រះ តបោវីយ៌្យ ត៑ បិ មោត៑ រាជ្យ អាយ៑ ស្រីសិខរីស្វរ ប្យ៑ ត៑ វ្រះតេជះ ប្រាទុភ៌ាវ ប្រត្យក្ស បិ លោក មេល៑ *ដែលអាចសម្រួលមកថា «ដោយកម្លាំងកិច្ចតបសដ៏ខ្លាំងក្លាដែលព្រះអង្គបានបំពេញ ព្រះបាទសូយ៌វម៌ (ទី១) បានជោគជ័យក្នុងការយាងស្រីភទ្រេស្វរជាទេពដែលគង់នៅលិង្គបូរ [៣៩] ឲ្យមកសោយរាជ្យនៅស្រីសិខរេស្វរ ដោយបញ្ចេញតេជះឲ្យជនទូទៅមើលឃើញច្បាស់នឹងភ្នែក [៤០]»។*

## ២.៥. សិលាចារឹកកបិលបូរ, K. 300, ស.វ.ទី១៣, ភាសាសំស្ក្រឹត [៤១]

*ចារឹកដ៏វែងនេះនិយាយពីឥសីព្រាហ្មណ៍ម្នាក់ឈ្មោះ* សវិជ្ញមុនិ *មកពីប្រទេសឥណ្ឌាមករស់នៅប្រទេសកម្ពុជា។ លោកបានសាងអាស្រមនិងបូជនីយស្ថាននៅទីកន្លែងមួយ។ ក្រោយមក ព្រះឥសូរក៏មកបង្ហាញខ្លួនឲ្យព្រាហ្មណ៍នោះឃើញនឹងភ្នែកស្រស់មួយភ្លែត ដើម្បីបញ្ចេញពាក្យពេចន៍អបអរពេញព្រះទ័យមុននឹងយាងបាត់ទៅវិញ។ ពីល្បះ២៥ទៅដល់ល្បះ៣៣ នៃផ្ទាំង A ខ្ញុំស្រង់ចេះយកតែពាក្យពេចន៍និងឃ្លាណាដែលទាក់ទង*

---

[៣៤] *ដោយរបៀបណា, យូរឬឆាប់, នៅរាជធានីអង្គរឬក៏នៅព្រះវិហារតែម្ដង... ទាំងនេះសុទ្ធសឹងជាចំណុចដែលយើងពុំដឹង។*

[៣៥] ភទ្រេស្វរ *ជានាមនៃទេពច្រើនផ្សេងៗគ្នានៅកម្ពុជាសម័យបុរាណ រាប់បញ្ចូលទាំងនៅវត្តភូ។ នៅទីនេះគេដឹងថាជាទេពធំនៃវត្តភូ។*

[៣៦] *នេះពុំមែនជាការដូរទីកន្លែងទេ គឺថាគង់ជាប្រចាំនៅវត្តភូផងនៅព្រះវិហារផង ក្នុងពេលជាមួយគ្នា។*

[៣៧] *កើតសាជាថ្មី។*

[៣៨] *សូមសង្កេតថា នៅប្រាសាទគោកចកខាងលើ (K. 521) គេប្រើពាក្យ* ប្រត្យាខេក *ដែលមានន័យប្រហាក់ប្រហែលគ្នាដែរ។*

[៣៩] លិង្គបុរ *ជាឈ្មោះមណ្ឌលវត្តភូ ប៉ុន្តែក៏ជាឈ្មោះក្រុងមួយចំនួននៅទីដទៃទៀតដែរ។*

[៤០] *គេប្រើពាក្យ* ប្រាទុភ៌ាវ ប្រត្យក្ស *ដូចមុននេះ ហើយថែមទាំងប្រើពាក្យ* មេល៑ *(មើល) ទៀត។*

[៤១] *Bergaigne 1893 : 581-582។*

នឹងប្រធានបទនេះប៉ុណ្ណោះ ៖

> ... លុះសាង [បូជនីយស្ថាន] នោះរួចហើយ [ព្រាហ្មណ៍សវ៌ជ្ញមុនិ] ឃើញព្រះមហេគូរ [៤២] មកបង្ហាញព្រះអង្គ ចែងចាំងប្រៀបបានទៅនឹងពេជ្រ (...) ជារូបរាងឲ្យមើលឃើញ តែដែលពិបាកសម្លឹងមើលជាប់យូរ (...)។ [ព្រាហ្មណ៍សវ៌ជ្ញមុនិ] លុតជង្គង់ប្រណម្យ (...) ដោយភ្ញាក់ផ្អើលយ៉ាងខ្លាំងបើកភ្នែកមើលទៅព្រះមហេគាន [៤៣] ដែលមានបន្ទូលមកថា «ល្អហើយ អ្នករស់នៅជាប់សង្វើងឥតគ្នីគ្នា [៤៤], ឯងទើបនឹងបានសាងមហាកុសលឲ្យអញ [៤៥] (...)។ លុះមានបន្ទូលដូច្នេះហើយ អទិទេពក៏បាត់ព្រះអង្គទៅ។

## ២.៦. សិលាចារឹកភូមិ Ban That (ខេត្តចម្បាសាក់, ប្រទេសលាវ), K. 364, ពាក់កណ្ដាលទី១ នៃស.វ.ទី១២, ភាសាសំស្ក្រឹត [៤៦]

ចារឹកមានបួនផ្ទាំងនេះជាកាព្យមួយយ៉ាងវែង។ របៀបបង្ហាញសេចក្ដីមានលក្ខណៈប្លែកខុសធម្មតា ដ្បិតជារឿងមួយដែលអ្នកនិពន្ធរៀបរាប់ក្នុងបែបបទដូចជាក្នុងល្ខោនអ្វីមួយ។ តួអង្គគឺជាម្ចាស់ចារឹកនេះឯង តែយើងមិនស្គាល់ឈ្មោះដោយសារថ្មត្រង់នោះបាក់បែក គ្រាន់តែដឹងថាជាព្រះ មុនិ មួយអង្គដែលប្រតិបត្តិតបសយោគនៅភ្នំភទ្រេស្វរ (វត្តភូ)។ បន្ទាប់មក ក្រោយពីជួបហេតុអស្ចារ្យមួយដែលយើងនឹងឃើញនៅខាងក្រោមនេះ លោកសាងលិង្គព្រះឥសូរធ្វើកិច្ចបូជានៅទីនោះ។ មិនយូរប៉ុន្មាន លោកមានឈ្មោះបោះសម្លេងល្បីល្បាញទៅដល់ព្រះរាជា ហើយទើបនាំគ្រួសារមកតាំងទីនៅកន្លែងមួយម្តុំភ្នំនេះ មានឈ្មោះជាសំស្ក្រឹតថា កុតស្ថាលី ឬជាខ្មែរ ឆោតិដ្ឋាន។

មួយផ្នែកក្នុងចារឹកហាក់ដូចជាធ្វើឲ្យអ្នកអានមានអារម្មណ៍ថារឿងនោះកើតក្នុងយុគមួយដែលមនុស្សនិងទេពជួបប្រាស្រ័យគ្នាផ្ទាល់ និយាយទាក់ទងគ្នាបានជាធម្មតា។ ឬមួយក៏អាចប្រដូចទៅរឿងព្រេងក៏សឹងថាបាន ដ្បិតព្រះមុនីនោះអះអាងថាលោកបានជួបព្រះឥសូរដែលជាអទិទេព ហើយបានជួបទេពដទៃទៀតដែលមានព្រះឥន្ទ្រជាអ្នកនាំមុខនៅលើទឹកដីមនុស្សតែម្តង។ ពោលឲ្យច្បាស់ទៅទៀតគឺថានៅបុរាណស្ថានវត្តភូនេះឯង។ ប្រវត្តិវិទូអាចច្បិចយកទិន្នន័យប្រវត្តិសាស្ត្រមួយចំនួនដែរ ដែលទាក់ទងនឹងរាជ្យព្រះបាទជ័យវម៌ទី៦, ធរណីន្ទ្រវម៌ទី១ និងសូយ៌វម៌ទី២។ ប៉ុន្តែខ្ញុំមិនលើកយកមកពិនិត្យទេ ដ្បិតនៅក្រៅប្រធានបទ។ រី

---

[៤២] ព្រះឥសូរ។

[៤៣] ព្រះឥសូរ។

[៤៤] ព្រាហ្មណ៍សវ៌ជ្ញមុនិជាតបសឫសី។

[៤៥] បូជនីយស្ថានអ្វីមួយដែលយើងមិនស្គាល់ តែដែលព្រាហ្មណ៍ សវិជ្ញមុនិ បានសាងថ្វាយព្រះឥសូរ។

[៤៦] *Finot 1912*។

ឯផ្នែកដែលចូលក្នុងប្រធានបទ ក៏ខ្ញុំសូមស្រង់ចេះយកតែមួយកន្លែងមកបង្ហាញដើម្បីឲ្យឃើញថា «អស្ចារ្យ» នោះអាចដល់ត្រឹមណា។

១៩ល្បះដំបូងនៃចារឹកនេះខូចខាតគ្មានសល់ ឯល្បះ១៨-២១ក៏ដូចគ្នា។ ទាល់តែដល់ល្បះ២២ទើបយើងដឹងថាព្រះឥសូរយាងចុះមកបង្ហាញព្រះអង្គចំមុខព្រះមុនី។ ល្បះ២៣-២៥ជាពាក្យពេចន៍នៃព្រះឥសូរផ្ទាល់ថ្លែងឆ្ពោះទៅព្រះមុនី ៖

> «អញតែងតាំងឯងនិងពូជឯងឲ្យទទួលបន្ទុកធ្វើកិច្ចបូជានៅលើផែនដីនេះតរៀងរហូតទៅ។ អញទុកលិង្គរបស់អញផ្ទាល់នៅលើភ្នំកម្រេងគូរក្នុងទឹកដីកម្ពុជទេសនេះតែម្តង។ បើឯងបូជាលិង្គនេះបានត្រឹមត្រូវ អញនឹងឲ្យឯងបានរួចផុតពីវដ្តសង្សារ (...)។ សូមឲ្យកិច្ចបូជាប្រចាំថ្ងៃដែលពូជឯងប្រតិបត្តិសម្រាប់រូបអញប្រព្រឹត្តិឡើងឥតមានដាច់រហូតដល់អវសានកាល។»

ព្រះមុនីរំភើបក្រៃលែង ដោយបានឃើញព្រះឥសូរផ្ទាល់នឹងភ្នែកហើយមានបន្ទូលមកកាន់ព្រះអង្គបែបនេះ។ ល្បះ២៦-២៧ ៖

> «(...) ចិត្តខ្ញុំពោរពេញទៅដោយសោមនស្ស ឥតសោកស្តាយការនិរទេសខ្លួនសោះឡើយ [៤៧]។ ទោះជាខ្ញុំក្លាយទៅជាដង្កូវឬសត្វល្អិតអ្វីមួយ ក៏នៅតែគ្រាន់បើជាងមានអំណាចគ្របតណ្តប់លោកដែរ (...)។»

## ២.៧. សិលាចារឹកភិមានអាកាស, K. 485, ឧសវត្ស ១១៩០, ភាសាសំស្ក្រឹត[៤៨]

នាងឥន្ទ្រទេវីដែលជាម្ចាស់ចារឹកនេះ ក្លាយមកជាមហេសីនៃព្រះបាទជ័យវរ្ម័ទី៧ តមកពីនាងជ័យរាជទេវីជាប្អូនស្រីដែលសុគតទៅ។ ពាក្យពេចន៍ទាំងប៉ុន្មានសុទ្ធសឹងជាពាក្យដែលបងស្រីពោលសរសើរពីប្អូន។

ខ្ញុំស្រង់យកល្បះ៦១-៦២មកបង្ហាញ ថ្វីបើបាត់អស់ពាក្យមួយចំនួនដោយសារថ្មបែក ដ្បិតព្រឹត្តិការណ៍ដែលរៀបរាប់ទាក់ទងនឹងប្រធានបទនេះ។ ព្រឹត្តិការណ៍នោះកើតឡើងតាំងពីមុនព្រះបាទជ័យវរ្ម័ទី៧ឡើងសោយរាជ្យម្ល៉េះ។ កាលនោះព្រះអង្គគង់នៅប្រទេសចម្ប៉ាមួយរយៈ ទុកព្រះជាយានៅឯស្រុកខ្មែរ។ ពាក្យដែលនៅសល់ក្នុងល្បះទាំងនេះធ្វើឲ្យគិតថា ពេលនោះនាងជ័យរាជទេវីកើតទុក្ខខ្លាំងណាស់ ហើយក៏ធ្វើកិច្ចតបសស្នឹងស្នាធិ៍តាមក្បួនព្រាហ្មណ៍អស់រយៈពេលណាមួយដែលយើងមិនដឹង ដើម្បីបានឃើញប្តីស្រស់ៗនឹងភ្នែក ៖

---

[៤៧] ការទៅតាំងទីនៅព្រៃភ្នំ រស់នៅជាតបសឬសី។

[៤៨] *Cœdès 1942 : 161-18*។

*... នាងឃើញភ្លើងសន្ធោសន្ធៅនៅក្នុងក្រឡាព្រះភ្លើង ... ដូច្នេះសម្រេចជោគជ័យដូចបានប៉ងប្រាថ្នាមែន ... ឃើញប្តីជាទីស្នេហានៅចំមុខ ស្រស់សង្ហាលើសព្រះគីគ្មទៅទៀត។ ទុក្ខញាំញីទាំងប៉ុន្មាននៅក្នុងចិត្ត ... ក្លាយទៅជាអារម្មណ៍សប្បាយរីករាយ។*

## ២.៨. សិលាចារឹកសម្រោង (ស្រុកពួក, ខេត្តសៀមរាប), K. 258, ដើមស.វ.ទី១២ [៤៩]

*គោលចារឹកយ៉ាងវែងជាភាសាខ្មែរនឹងសំស្ក្រឹតនេះ និយាយរឿងច្រើនដាច់ៗគ្នា។ សម្រង់ខាងក្រោមនេះជាសំដីនៃ យោគីគុរបណ្ឌិត ដែលជាម្ចាស់សិលាចារឹក ៖*

១០១៨ ឝក គិ នុ អំតេង ត មូល វ្រះ ចៅ នុ អំតេង ឝ្រីយុវរាជ វ្រះ ចៅ អញ្ជេញ អញ ប្រយឝ្ចិត [៥០] - ផ្ទៃ ចុះ អគ្និ [៥១] ត ប្រាសាទ- ទេប សិច ទិក ត តៃ *សម្រួលមកថា «នៅឆ្នាំ១០១៨ [៥២] អំតែងជាមេ, ព្រះចៅ និង អំតែងស្រីយុវរាជព្រះចៅ បានអញ្ជើញខ្ញុំឲ្យធ្វើកិច្ចរម្ងាប់បង្ក័ក់ប្រាសាទដែលត្រូវរន្ទះបាញ់ ហើយអ្នកទាំងពីរបានសិតទឹកលើដៃខ្ញុំ» [៥៣]។*

## ២.៩. សិលាចារឹកប្រាសាទកែវ, K. 277, ភាសាខ្មែរ, ស.វ.ទី១១ [៥៤]

យោគីគុរបណ្ឌិតជាម្ចាស់សិលាចារឹកនេះ មាននាមដូចម្ចាស់ *K. 258* ខាងលើនេះដែរ តែពុំមែនជាមនុស្សដដែលឡើយ។ ឈ្មោះហៅឲ្យពេញគឺ យោគីគុរបណ្ឌិត ស្រុក វ្នរ កម្ទេត (ដែលមានកំណើតនៅភូមិទួលកន្ទួត)។ គាត់ជាព្រះរាជគ្រូនៃព្រះបាទសូយ៌វម៌ទី១។

*ចារឹកនេះក៏និយាយពីរន្ទះបាញ់ប្រាសាទដែរ គឺបាញ់ប្រាសាទកែវក្នុងឧទ្យានអង្គរដែលកំពុងតែសង់ ៖* មជិ ចុះ អសុជិ ... ប្រាសាទ គិ នុ ថ្ងៃ ប្រាយឝ្ចិត្ត មជិ ប្រារម្ភ សម្រេច វ្រះ ប្រាសាទ ទុញ ថ្ម... *សម្រួលមកថា «រន្ទះបាញ់ត្រូវប្រាសាទ [ហេតុនេះ] គេធ្វើកិច្ចរម្ងាប់បង្ក័ក់ បន្ទាប់មកគេចាប់ផ្តើមសាងជា*

---

[៤៩] *Cœdès 1954 : 175-205*។

[៥០] ប្រាយឝ្ចិត្ត (សំ.) *អាចប្រែថា «រម្ងាប់», «បង្ក័ក់»*។

[៥១] អគ្និ (សំ.) *គឺ «រន្ទះ», «ផ្ទេកបន្ទោរ»*។

[៥២] *ត្រូវនឹងគ.ស. ១០៩៦*។

[៥៣] *នាបច្ចុប្បន្ននេះក៏ដោយ គេនៅតែចាត់ទុករន្ទះបាញ់ផ្ទះឬក៏ភូមិផ្ទះថាជាឧត្បាតចង្រៃ ហើយគេតែងតែធ្វើកិច្ចបញ្ចៀសផលអាក្រក់នោះឲ្យអស់។ រីឯការដែលម្ចាស់បុណ្យ (អំតែងទាំងពីរនាក់) សិតទឹកលើដៃអ្នកធ្វើកិច្ច (យោគីសូរបណ្ឌិត) វិញ សព្វថ្ងៃនេះប្រហែលជានៅតែមានធ្វើនៅទីខ្លះដែរ ដោយប្រើទឹកត្រាំផ្លែសម្បួរ។ ឯខ្ញុំផ្ទាល់ ធ្លាប់ឃើញតែគេចងដៃឲ្យអាចារ្យ នៅពេលធ្វើកិច្ចហើយ។*

[៥៤] *Cœdès 1952 : 155-160*។

*បញ្ចប់ ដោយទិញថ្ម...»* [៥៥]។

## ២.១០. សិលាចារឹកបដ្ហាយទ្វារ, K. 1313, គ.ស. ១២១៦, ចំណាងជើងជាខ្មែរ, សេចក្ដីទាំងអស់ជាសំស្រ្កឹត

*ចំណារ៤បន្ទាត់នៅលើមេទ្វារនេះជាភាសាសំស្រ្កឹត តែនៅលើនោះមានចំណងជើងជាខ្មែរថា ព្រះវ្លេងស្វគ្គ (ព្រះភ្លើងសួគ៌)។ ដោយសារសេចក្ដីទាំងមូលពុំវែងប៉ុន្មានខ្ញុំយកសេចក្ដីប្រែជាភាសាអង់គ្លេស[៥៦]មកប្រែជាខ្មែរហើយចុះនៅទីនេះទាំងស្រុង ៖*

> *ប្រះវ្លេងស្វគ៌*
>
> *ខ្ញុំ, ស្រីមធុរេន្ទ្រសុរី, បានឃើញភ្លើងនេះធ្លាក់ចុះពីលើមេឃមកដល់ទីនេះ នៅពេលដែលព្រះស្រីវីរគត្តិមកដល់នៅឆ្នាំ១១៣៨ [៥៧]។ ខ្ញុំបានឃើញភ្លើងឆេះឡើងក្នុងលំហមេឃធ្លាក់ពីស្ថានសួគ៌ចុះមកនៅអាណាចក្រនៃព្រះស្រីជយវម៌្ម [៥៨]។ នេះជាបាតុភូតអស្ចារ្យមួយដែលខ្ញុំជឿថានឹងឲ្យផលគាប់ប្រសើរ ពោលគឺមានកំណើតរុងរឿង, ប្រកបដោយភ្នែកពីរដ៏ភ្លឺថ្លា, ក្នុងត្រកូលខ្ពង់ខ្ពស់។ សូមឲ្យខ្ញុំបានជួបនឹងប្រការទាំងនេះ!*

*ក្នុងការសិក្សាដ៏សំខាន់យ៉ាងវែងមួយនៃចារឹកដែលមានតែ២ល្បះនេះ លោក Thomas Maxwell មានការពិចារណានិងបង្ហាញទឡ្ហីករណ៍ល្អិតល្អន់ខ្លាំងណាស់ តែលោកមិនធានាថាបានថាសុក្រឹតពេញលេញទេ ដ្បិតមានការស្មានច្រើននៅឡើយ។ លោកបង្ហាញថាស្រីមធុរេន្ទ្រសុរីជា ហោត្រ ពោលគឺជាបព្វជិតឬអាចារ្យដែលគ្រប់គ្រងកិច្ចបូជាព្រះភ្លើងនៅបន្ទាយឆ្មារ។ ខ្ញុំគ្រាន់តែស្រង់ចេះយកចំណុចខ្លះៗដែលខ្ញុំស្របតាម ហើយបញ្ចេញគំនិតបន្តិចបន្តួចដែលទាក់ទងនឹងប្រធានបទនេះ ៖*

*- «ព្រះភ្លើងសួគ៌» ដែល «ចុះមក» នោះពុំមែនជារន្ទះឡើយ [៥៩]។ ក្នុងសេចក្ដីសំស្រ្កឹតក៏គេគ្រាន់តែប្រើពាក្យ* អគ្និ *ដែរ ៖* អគ្និរ៑ ទិវះ បតត *(«ភ្លើងធ្លាក់ចុះពីសួគ៌»)។ ប្រសិនបើជាភ្លើងរន្ទះ គឺច្បាស់ជាគេប្រើពាក្យ*

---

[៥៥] *យើងឃើញថាបានធ្វើកិច្ចរម្ងាប់ហើយក្ដី ប្រាសាទកែវនៅតែមិនបានសាងចប់ចុងចប់ដើម មានតែតួខ្លួន តែឥតមានចម្លាក់ក្បាច់លំអដល់សព្វថ្ងៃ។*

[៥៦] *Maxwell 2009។*

[៥៧] *គ.ស.១២១៦។*

[៥៨] *ព្រះបាទជ័យវរ្ម័នទី៧។ អាណាចក្រនៃព្រះស្រីជយវម៌្ម (សំ. ស្រីជយវម៌្មរាជ្យ) ត្រង់នេះសំដៅប្រាសាទបន្ទាយឆ្មារដែលសាងឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។*

[៥៩] *ប្រសិនបើបាតុភូតនេះមានកើតឡើងមែន តើជាដុំភ្លើងថ្មហៅថា météorite / aérolithe ឬយ៉ាងណា ?*

អគ្និ, អស្សុនិ (< អគនិ) ដូចនៅ *K. 258* និង *K. 277* ដែលយើងទើបនឹងឃើញមកមុននេះ។ គេឥតមាននិយាយពីកិច្ចពិធីបង្កក់រម្ងាប់អ្វីទាំងអស់ ខុសពីនៅចារឹកទាំងពីរដដែល។ ម្យ៉ាងទៀតសូមរំឭកឡើងវិញថានៅ *K. 484* (ភិមានអាកាស, ចំណុច២.៣) គេបន់ស្រន់សូមកុំឲ្យមានរន្ទះមកបាញ់ព្រះពោធិ ៖ គាំ ឞិ វន្ទះ បញ្ចា ដែលបង្ហាញថារន្ទះជាប្រការចង្រៃ ដូចក្នុងជំនឿនាបច្ចុប្បន្ននេះដែរ។

- ធ្លាក់ចុះពីលើមេឃមកដល់ទីនេះ ៖ «ទីនេះ» ប្រហែលជាសំដៅថាដុំភ្លើងធ្លាក់ពីលើមកក្នុងបរិវេណឬក៏ម្តុំជុំវិញប្រាសាទបន្ទាយឆ្មារ ឬអាចស្មានម្យ៉ាងទៀតថាធ្លាក់នៅត្រង់ចំណុចដែលបន្ទាប់មកគេសង់ក្តីតម្កល់ព្រះភ្លើងនោះឯង។

- វ្រះ ស្រីវីរឝក្តិះ ក្នុងការសិក្សាលើព្រះស្រីវីរសក្តិ អ្នកប្រាជ្ញពីមុនមកផ្អែកមូលដ្ឋានលើសិលាចារឹកមួយចំនួន ជាពិសេសលើមូលចារឹកប្រាសាទតាព្រហ្ម (*K. 273*, ល្បះ៨៥), ប្រាសាទព្រះខ័ន (*K. 908*, ល្បះ ១១២ និង១៥៩) និងវត្តនគរ (*K. 82*, បន្ទាត់១០-១១)។ ការសិក្សាដ៏វែងឆ្ងាយនេះមិនចូលចំក្នុងប្រធានបទនេះឡើយ។ យើងគ្រាន់តែត្រូវដឹងថា ក្នុងរាជ្យព្រះបាទជ័យវរ្ម័ទី៧ ជារៀងរាល់ឆ្នាំ ក្នុងខែផល្គុននិងចេត្រគេធ្វើបុណ្យដង្ហែរយ៉ាងអធិកអធមនូវប្រតិមាមកពីទីផ្សេងៗចូលមកឆ្លងកាត់ប្រាសាទតាព្រហ្ម, ប្រាសាទព្រះខ័ននិងបន្ទាយឆ្មារជាដើម។ ក្នុងចំណោមប្រតិមាទាំងនោះ មួយអង្គជាព្រះពុទ្ធដែលមាននាមថា ស្រីវីរឝក្តិ ហើយដែលជាធម្មតាតម្កល់នៅប្រាសាទវត្តនគរ (កំពង់ចាម)[៦០]។ សារៈសំខាន់ដែលស្រីមធុរេន្ទ្រសុរីចង់បង្ហាញនៅត្រង់ថា ពេលដែលគេហែរព្រះស្រីវីរសក្តិមកដល់បន្ទាយឆ្មារនៅឆ្នាំ១២១៦ គឺពេលនោះឯងតែម្តងដែលគាត់ឃើញព្រះភ្លើងសួគ៌ធ្លាក់ចុះមក។ មានន័យថាជាបាតុភូតមួយដែលអស្ចារ្យ ពោលគឺពុំមែនជាការចៃដន្យឡើយ។

## ២.១១. សិលាចារឹក K. 1457, ឥតកាលបរិច្ឆេទ, ភាសាសំស្ក្រឹតនិងខ្មែរ[៦១]

យើងដឹងថាចារឹកទាំងអម្បាលម៉ានដែលមាននិយាយពីព្រះបាទជ័យវរ្ម័ទី៣ សុទ្ធសឹងចារក្រោយរាជ្យនោះទាំងអស់។ ដូច្នេះហើយបានជាគេនិយាយពីព្រះអង្គតែតាមមរណនាម ពោលគឺ វិស្ណុលោក។ រីឯ *K. 1457* ដែលគេទើបនឹងរកឃើញប៉ុន្មានឆ្នាំមុននេះក៏ដូចគ្នា ហើយគ្មានទាំងកាលបរិច្ឆេទទៀតផង។ ចារឹកនេះនិយាយពីព្រឹត្តិការណ៍អស្ចារ្យពីរដែលទាក់ទងគ្នា ។ គោលបំណងនៃការតែងប្រឌិតនោះលេចធ្លោផាយយល់ណាស់ គឺទីមួយគេលើកតម្កើងនិកាយ វៃ្លស្ណវ ក្នុងព្រហញ្ញសាសនាដែលទុកព្រះនារាយណ៍ជាសំខាន់លើគេ ទីពីរដើម្បីពន្យល់ថាហេតុអ្វីបានជាព្រះបាទជ័យវរ្ម័ទី៣នៅក្នុងនិកាយនេះ។ ពីមុនមក យើងគ្រាន់តែប្ញែកក្នុងចិត្តបន្តិចថាព្រះបាទជ័យវរ្ម័ទី២ជាបិតាកាន់និកាយគៃវ ដែលទុកព្រះឥសូរជាធំដូចមានមរណនាមឲ្យយើងយល់ស្រាប់៖ បរមេឝ្វរ។ ដូច្នេះឃើញថាឪពុកនិងកូនកាន់ខុសគ្នា។

- ហេតុអស្ចារ្យទី១ ៖ ល្បះ៣នៃចារឹកនិយាយថា «(...) ដោយសារប្រការអ្វីមួយ ព្រះអង្គពុំសប្បាយ

---

[៦០] ក្នុងការពិភាក្សាល្អិតវែងឆ្ងាយ សូមមើល Maxwell 2009 : 180-185។

[៦១] Goodall and Hun 2021 : 266-295។

ព្រះទ័យនឹង [សាសនា] ព្រះពុទ្ធ ទើបដេញពុទ្ធសាសនិកឲ្យចេញឆ្ងាយ ហើយឲ្យប្រជារាស្ត្រទូទៅកាន់លទ្ធិសៃវៈ»[៦២]។ ព្រះគ្រូនៃព្រះរាជាដែលមាននាមថា កុលចន្ទ្រ ពុំជឿថាមានព្រះព្រហ្មនិងព្រះនារាយណ៍ឡើយ គឺថាមានតែព្រះឥសូរមួយអង្គប៉ុណ្ណោះ (ល្បះ៤)។ ល្បះ៥-៦ បង្ហាញពីបព្វជិតខាង វ៉ៃគ្ណវ មួយអង្គដែលគោរពព្រះក្រឹស្ណាជាធំ [៦៣]ហើយជាអ្នកកាន់កាប់កិច្ចពិធីនៅ គ្រីចាម្បេគ្វរ [៦៤]។ នាមព្រះអង្គគឺ ក្រិស្ណបាល។ ពេលមួយនោះមានការជជែកវែកញែករកឈ្នះចាញ់រវាង កុលចន្ទ្រ នឹង ក្រិស្ណបាល ហើយក្នុងពេលនោះ កុលចន្ទ្រ ចាញ់ដោយអណ្ដាតខ្លួនឯងនោះដាច់រយះចេញពីគ្នាពេលកំពុងនិយាយ ដោយអនុភាពនៃព្រះនារាយណ៍ដែលគង់ក្នុងបេះដូង ក្រិស្ណបាល (ល្បះ៧-៨)។ ព្រះរាជា (ព្រះបាទជ័យវម៌ទី៣) យល់បាដិហារ្យស្ដែងដូច្នោះ ក៏ដាក់ព្រះអង្គទៅជាសាសនិកខាងនិកាយព្រះនារាយណ៍តាំងអំពីនោះមក។ ព្រះរាជាប្រទានប្រតិមាព្រះនារាយណ៍មួយអង្គទៅ ក្រិស្ណបាល ដើម្បីឲ្យមនុស្សទូទៅគោរពវន្ទាពីពេលនោះតទៅ [៦៥]។

- ហេតុអស្ចារ្យទី២ ៖ រឿងពុំចប់តែត្រឹមនេះទេ។ ពេលក្រោយមកទៀត ព្រះជាយានៃព្រះបាទជ័យវម៌ទី៣[៦៦] យាងចូលមកប្រាសាទដែលមានតម្កល់ប្រតិមាអម្បាញ់មិញ ក្នុងឱកាសបុណ្យមួយ។ បញ្ហានៅត្រង់នេះ គឺយាងចូលមកក្នុងប្រាសាទក្នុងពេលដែលនាងមានរដូវ។ ពេលនោះឈាមហូរចេញពីសុដន់នាង ដោយសារព្រះនារាយណ៍ខ្ញាល់។ នាងក៏ទៅជាឈឺស្គមស្គាំង រហូតដល់ព្រះស្វាមីថ្វាយនាងទៅព្រះនារាយណ៍តែម្ដង [៦៧]។ ជាមួយគ្នានោះ ព្រះអង្គធ្វើតង្វាយទៅដល់ទេពនារាយណ៍នូវខ្ញុំស្រីប្រុស ព្រមទាំងដីធ្លីសន្ទឹកសន្ធាប់ (ល្បះ១៥-១៧)។ ក្រោយមក ដោយយល់ថាពិរោធនៃទេពបានស្រាកស្រាន្តហើយ ព្រះរាជាក៏ប្រគល់ព្រះជាយា (ដែលបានស្រាកស្រាពីជម្ងឺដែរ)ឲ្យទៅជាករិយានៃអាចារ្យធ្វើកិច្ចប្រចាំបូជនីយស្ថាននេះ។ អាចារ្យដែលមានឈ្មោះឬងាររថា ធម៌ធ្វ នេះក៏ជាសាច់ឈាមក្នុងពូជពង្ស ក្រិស្ណបាល ដែរ (ល្បះ១៨)។

រឿងទាំងពីរគន្ទាក់នេះកើតឡើងដល់ត្រឹមណាពិតប្រាកដនោះមិនសំខាន់អ្វីឡើយ ប្រការដែលសំខាន់គឺគេចង់បង្ហាញថា ក្នុងដំណើរជីវិតព្រះអង្គ ពេលណាមួយនោះព្រះបាទជ័យវម៌ទី៣ដែលធ្លាប់តែជាសៃវាក៏

---

[៦២] នេះជាកាយវិការមួយមានដោយកម្រ ដ្បិតជាធម្មតាព្រះរាជាច្រើនតែរាប់រកពុទ្ធសាសនិកហើយជួយផ្គត់ផ្គង់សាសនានេះឲ្យចម្រុងចម្រើនផង។

[៦៣] ក្រិស្ណ ជាអវតារមួយនៃព្រះនារាយណ៍ តែទេពកឋាជាច្រើនហាក់ដូចទុកព្រះអង្គថាជាព្រះនារាយណ៍តែម្ដង ពុំមែនគ្រាន់តែបែងភាគអ្វីឡើយ។

[៦៤] លោក G. Cœdès តែងនិយាយនៅច្រើនកន្លែងថា ចាម្បេគ្វរ នេះអាចជាប្រា.គោកពោធិដែលស្ថិតនៅខាងពាយ័ព្យឧទ្យានអង្គរ។

[៦៥] យើងពុំដឹងថាមានសាងបូជនីយស្ថានអ្វីមួយដើម្បីតម្កល់ប្រតិមានោះឬមួយគ្រាន់តែតម្កល់ក្នុងប្រាសាទណាមួយដែលមានស្រាប់។

[៦៦] ចារឹកឥតមានប្រាប់ព្រះនាមទេ។

[៦៧] ថ្វាយឲ្យនៅបម្រើប្រាសាទនោះ ជាមួយនឹងខ្ញុំឯទៀត ?

*ចាប់ផ្ដើមជ្រើសរើសយកគន្ធមួយផ្សេងពីឪពុក។*

### ២.១២. សិលាចារឹកភ្នំដី (ស្រុកអង្គរជុំ, ខេត្តសៀមរាប), K. 1222, ស.វ.ទី១២, ភាសាសំស្ក្រឹត

*មកទល់ត្រឹមនេះ បាតុភូត «អស្ចារ្យ» ច្រើនតែកើតឡើងឲ្យមនុស្សម្នាក់ឬមនុស្សច្រើននាក់បាន យល (គឺថាឃើញក្នុងសប្តិក្តី ដោយស្តែងពិតៗនឹងភ្នែកក្តី)។ បាតុភូតនេះឡើងខ្លាំងមួយកម្រិតទៅទៀតនៅ K.300 (ចំណុច២.៥), ជាពិសេសនៅ K. 364 (ចំណុច២.៦) ដ្បិតទេពបង្ហាញខ្លួននិយាយឆ្លើយឆ្លងជាមួយមនុស្សស្រស់ៗ។*

*ក្នុង K. 1222 ដែលយើងសង្ខេបសេចក្តីមួយភាគតូចមកបង្ហាញនៅទីនេះ កម្រឹតអស្ចារ្យនោះឡើងដល់កំពូល។ ចារឹកនេះមាន៤ផ្ទាំងហៅតាមទិស ដែលអ្នកស្រាវជ្រាវមួយក្រុមកំពុងសិក្សា ហើយនឹងចេញផ្សព្វផ្សាយក្នុងពេលខាងមុខឆាប់ៗ[៦៨]។ ផ្ទាំងខាងកើតមួយផ្នែកធំនិយាយពីព្រាហ្មណ៍ខ្ពង់ខ្ពស់ម្នាក់ឈ្មោះ មធុរេន្ទ្រ។ ប្រការមួយចម្លែកខ្លាំង គឺចារឹកអះអាងថាព្រាហ្មណ៍នេះជាព្រះឥសូរតែម្តង (មហេឝ្វរ) ដែលយាងមកចាប់ជាតិលើដីដើម្បីបង្រៀនព្រះបាទសូយ៌វម៌ទី២ក្នុងឋានៈជា មហារាជគុរុ (ល្បះ១៧)។ ក្រៅពីព្រះរាជា ព្រះគ្រូនេះមានសិស្សរាប់រយដែលចុះមកចាប់ជាតិលើដីដូចគ្នា។ លុះអស់ជន្មាយុទៅ ព្រះគ្រូនិងសិស្សទាំងនេះរលាយប្រាណទៅជាលិង្គនៅមាត់ស្ទឹងមួយឈ្មោះ ចឝម្ព (ល្បះ២២-២៣)។*

---

[៦៨] *ខ្ញុំបានទទួលការអនុញ្ញាតិពីលោក D. Goodall ដែលនៅក្នុងក្រុមនោះឲ្យប្រើប្រាស់សេចក្តីប្រែបណ្តោះអាសន្នរបស់លោក។*

# ឯកសារពិគ្រោះ


ANG, Chouléan.

- « Les apparition de fantômes au Cambodge», *Cheminements*, *ASEMI* XI, 1-4, Paris (1980): 437-443.
- *Les êtres surnaturels dans la religion populaire khmère*, Cedoreck, Paris, 1982.
- « Nostalgia or Appropriation of the South? », *in* Sonya Rhie Mace and Bertrand Porte Eds.: *Revealing Krishna*, The Cleveland Museum of Art (in association with D Giles Limited, London) (2021): 163-174.

AYMONIER, Étienne. «Notes sur les coutumes et les croyances superstitieuses des Cambodgiens», *Excursions et Reconnaissances* 16, Challamel, Paris (1883): 133-220.

BERGAIGNE, Abel. « Inscriptions sanscrites du Cambodge », *Notices et extraits des manuscrits de la Bibliothèque nationale et autres bibliothèques*, t. XVII, fasc. 2 (1893) : 560-588.

BRANDA, Paul. *Çà et là. Cochinchine et Cambodge*, Fischacher, Paris, 1887.

CŒDÈS, George.

- « Études cambodgiennes. XIV. Une nouvelle inscription du Phimanakas», *BEFEO* XVIII, 9 (1918) : 9-12.
- *Inscriptions du Cambodge*, t. I, éditées et traduites par, EFEO, Hanoï, 1937.
- *Inscriptions du Cambodge*, t. II, Hanoï, 1942.
- *Inscriptions du Cambodge*, t. IV, Paris, 1952.
- *Inscriptions du Cambodge*, t. VI, Paris, 1954.

FINOT, Louis. « Notes d'épigraphie. XIII. L'inscription de Ban That », *BEFEO* XII, 2 (1912): 1-28.

GOODALL, Dominic and HUN, Chhunteng. « Sectarian Rivalry in Ninth-Century Cambodia : A Posthumous Inscription Narrating the Religious Tergiversations of Jayavarman III (K. 1457) », *Medieval Worlds* 13 (2021): 266-295.

MAXWELL, Thomas. S. "A new Khmer and Sanskrit inscription at Banteay Chmar", *UDAYA* 10 (2009): 134-201.

MENAUT, B. *Matière médicale cambodgienne*, Imprimerie d'Extrême-Orient, Hanoï, 1930.

MONIER-WILLIAMS, Monier. *A Sanskrit-English Dictionary*, Oxford University Press, London, 1899.

STCHOUPAK, N., NITTI, L., RENOU, L. *Dictionnaire sanskrit- français*, Librairie Maisonneuve, Paris, 1959.

*ប៉ិច វុទ្ធី (អ្នកស្រី). បទសម្ភាសន៍ធ្វើឡើងនៅឆ្នាំ១៩៨១ នាក្រុងប៉ារីស៍។*